ឈ្មោះអតិថិជន ____________________
លេខករណី ____________________
កាលបរិច្ឆេទ ____________________
ខោនធី ____________________
លេខទូរស័ព្ទខោនធី ____________________

# វិធានសម្រាប់ករណី CalWORKs របស់លោកអ្នក បានផ្លាស់ប្តូរ។ សូមអានព័ត៌មាននេះដោយប្រុងប្រយ័ត្ន។

មកដល់ថ្ងៃទី_______________( កាលបរិច្ឆេទ ) សំណុំរឿង CalWORKs របស់លោកអ្នក នឹងផ្លាស់ប្តូរពីការរាយការណ៍ប្រចាំឆ្នាំទៅជាការរាយការណ៍ប្រចាំឆមាស ពីព្រោះឥឡូវនេះ សំណុំរឿងរបស់លោកអ្នករួមបញ្ចូលទាំងជំនួយ សម្រាប់មនុស្សពេញវ័យដែ លមានគុណវឌ្ឍ។ ក្រោមការរាយការណ៍ ប្រចាំ ឆមាស លោកអ្នកត្រូវបានតម្រូវឲ្យរាយការណ៍ពីរលើកក្នុងមួយឆ្នាំ ជំនួសឲ្យ មួយលើកក្នុងមួយឆ្នាំ។ របាយការណ៍មួយក្នុងចំណោមរបាយការណ៍ទាំងនោះ គឺជាទម្រង់កំណត់គុណវឌ្ឍឡើងវិញប្រចាំឆ្នាំ/ទម្រងបញ្ជាក់សារជាថ្មី (SAWS 2 PLUS) របស់លោកអ្នក។ ប្រាំមួយខែក្រោយពីលោកអ្នកបានបំពេញ SAWS 2 PLUS របាយការណ៍ស្តីពីស្ថានភាពគុណវឌ្ឍប្រចាំឆមាស (SAR 7) នឹងត្រូវបានផ្ញើជូនលោកអ្នក ដែលនឹង ជម្រាបប្រាប់លោកអ្នកអំពីពេលវេលាដល់កំណត់ត្រូវធ្វើ។ លោកអ្នកមិនចាំបាច់រាយការណ៍ ពេលដែលអ្នកណាម្នាក់ចូលមកនៅឬចេញពីផ្ទះលោកអ្នកទេ រហូតដល់ពេលធ្វើរបាយការណ៍បន្ទាប់ (SAWS 2 PLUS ឬ SAR 7) របស់លោកអ្នកដល់កំណត់ វិធាន ស្តីពីការរាយការណ៍កម្រិតប្រាក់ចំណូល (IRT) គឺដូចគ្នាក្រោមការរា យការណ៍ប្រចាំឆមាសៈ នៅពេលលោកអ្នករាយការណ៍ពីប្រាក់ចំណូលលោកអ្នកបានលើស IRT នោះ ខោនធី អាចបន្ថយឬបញ្ឈប់អត្ថប្រយោជន៍របស់លោកអ្នក។

សេចក្តីជូនដំណឹងនេះបញ្ជាក់លម្អិតអំពីលក្ខខណ្ឌតម្រូវក្នុងការធ្វើការរាយការណ៍ប្រចាំឆមាស។ សាកសួរបុគ្គលិកសង្គមកិច្ចរបស់លោកអ្នក ឬហៅទូរស័ព្ទទៅកាន់ខោនធី ប្រសិនបើលោកអ្នកមានសំណួរអំពីអ្វីដែលត្រូវរាយការណ៍ និងពេលណាដែលត្រូវរាយការណ៍។

លោកអ្នកនឹងទទួលបានសេចក្តីជូនដំណឹងដាច់ដោយឡែកមួយអំពីការផ្លាស់ប្តូរទាំងឡាយទាក់ទងនឹងលក្ខខណ្ឌតម្រូវក្នុងការរាយការណ៍អំពី CalFresh។

## វិធានការរាយការណ៍

ក្រោមការរាយការណ៍ប្រចាំឆ្នាំ លោកត្រូវបានតម្រូវឲ្យបំពេញទម្រង់កំណត់ គុណវឌ្ឍឡើងវិញសម្រាប់អត្ថប្រយោជន៍ប្រចាំឆ្នាំប៉ុណ្ណោះ។ ក្រោមការរាយការណ៍ប្រចាំឆមាស បន្ថែមទៅនឹងការកំណត់គុណវឌ្ឍឡើងវិញប្រចាំឆ្នាំ លោកអ្នកត្រូវបានតម្រូវឲ្យប្រគល់ទម្រង់ SAR 7 មួយឆ្នាំម្តង ( ៦ខែក្រោយពីការកំណត់គុណវឌ្ឍឡើងវិញប្រចាំឆ្នាំរបស់លោកអ្នក )។ ទម្រង់ SAR 7 នឹងត្រូវផ្ញើជូនលោកអ្នកតាមប្រៃសណីយ៍។

ដូចការរាយការណ៍ប្រចាំឆ្នាំដែរ លោកអ្នកនឹងទទួលលិខិតណាត់ជួបនៅក្នុងសំបុត្រប្រៃណីយ៍ កាលណាដល់ពេលកំណត់ធ្វើការកំណត់គុណវឌ្ឍរបស់លោកអ្នកឡើងវិញ។ ប្រសិនបើលោកអ្នកខកខានការណាត់ជួបទាក់ទងនឹងការកំណត់គុណវឌ្ឍឡើងវិញ ហើយមិនកំណត់ពេលណាត់ជួបនៅចុងខែៈជំនួយរបស់លោកអ្នកនឹងបញ្ឈប់។

ឧទាហរណ៍ៈ នៅថ្ងៃទី18 ខែមីនា លោកអ្នកទទួលលិខិតណាត់ជួបពីខោនធី ដែលនិយាយថា ការណាត់ជួបទាក់ទងនឹងការកំណត់គុណវឌ្ឍឡើងវិញរបស់លោកអ្នកនឹងត្រូវធ្វើនៅថ្ងៃទី4 ខែមេសា។ ប្រសិនបើលោកអ្នកខកខានការណាត់ជួបនេះ ហើយមិនណាត់ជួបនៅចុងខែមេសា ព្រោះសំណុំរឿងរបស់លោកអ្នកនឹងត្រូវបញ្ឈប់នៅថ្ងៃ ទី30 ខែមេសា។

## វិធានរាយការណ៍អំពីកម្រិតប្រាក់ចំណូល (IRT)

បរិមាណប្រាក់ចំណូល ដែលលោកអ្នកត្រូវរាយការណ៍ក្នុងរយៈពេល 10 ថ្ងៃ នឹងបិតនៅដដែល ក្រោមការរាយការណ៍ប្រចាំឆមាស។ ប្រសិនបើប្រាក់ចំណូលសរុបប្រចាំខែលោកអ្នកមានចំនួនច្រើនជាងចំនួន IRT របស់លោកអ្នក លោកអ្នកត្រូវរាយការណ៍អំពីប្រាក់ចំណូលជូនខោនធី ក្នុងរយៈពេល10ថ្ងៃ។ ពាក្យថា ប្រាក់ចំណូលសរុបប្រចាំខែ" យើងចង់មានន័យថា លុយអ្វីក៏ដោយដែលលោកអ្នកទទួលបាន។ ខោនធីនឹងជម្រាបប្រាប់លោកអ្នកអំពីអ្វីទៅជា IRT លោកអ្នក។ ក្រោមការរាយការណ៍ប្រចាំឆមាស IRT គឺនៅតែផ្អែកលើប្រាក់ចំណូលសរុបរបស់លោកអ្នក និងចំនួនមនុស្សនៅក្នុងគ្រួសាររបស់លោកអ្នក។ ការមានចំណូលលើស IRT អាចនាំឲ្យជំនួយរបស់លោកអ្នកថយចុះ ឬជំនួយលោកអ្នកត្រូវបញ្ឈប់។

ឧទាហរណ៍ ប្រសិនបើប្រាក់ IRT លោកអ្នកមានចំនួន $1000 ហើយ លោកអ្នកទទួលបានប្រាក់ចំណូល $800 នោះលោកអ្នកមិនចាំបាច់រាយការណ៍អំពីការផ្លាស់ប្តូររហូតដល់របាយការណ៍លើកក្រោយ (SAR 7 ឬ SAWS 2 PLUS) របស់លោកអ្នក។ ប្រសិនបើលោកអ្នកទទួលបានប្រាក់ចំណូល $1001 ឬច្រើនជាងនេះ នោះលោក អ្នកត្រូវរាយការណ៍ទៅបុគ្គលិកសង្គមកិច្ចរបស់លោកអ្នកក្នុងរយៈពេល 10ថ្ងៃ។ ប្រសិនបើប្រាក់ចំណូលនេះនៅបន្តឡើងដូច្នេះ ជំនួយអត្ថប្រយោជន៍សាច់ប្រាក់របស់លោកអ្នក នឹងត្រូវបន្ថយ ឬបញ្ឈប់ក្នុងរយៈពេល 10ថ្ងៃនៃការជូនដំណឹង។

## វិធានរាយការណ៍ជាចាំបាច់

វិធានរាយការណ៍ជាចាំបាច់នៃ CalWORKs ភាគច្រើនគឺដូចគ្នា ក្រោមការរាយការណ៍ប្រចាំឆមាស និងក្រោមការរាយការណ៍ប្រចាំឆ្នាំដែរ។ វិធានរាយការណ៍ប្រចាំឆមាសចែងថា លោកអ្នក**ត្រូវតែរា**យការណ៍អំពីការផ្លាស់ប្តូរដោយផ្ទាល់មាត់ ឬជាលាយលក្ខណ៍អក្សរក្នុងរយៈពេល 10ថ្ងៃនៃការផ្លាស់ប្តូរ ដូចខាងក្រោម៖

- ប្រាក់ចំណូលលើស IRT
- ការផ្លាស់ប្តូរអាសយដ្ឋាន
- ស្ថានភាពជាឧក្រិដ្ឋជនដែលរត់គេចខ្លួន ឬ
- រំលោភលក្ខខណ្ឌនៃរយៈពេលកំណត់កែប្រែខ្លួន ឬការដោះលែងឲ្យនៅក្រៅឃុំដោយមានលក្ខខណ្ឌ។

## វិធានរាយការណ៍ដោយស្ម័គ្រចិត្ត

ក្រោមការរាយការណ៍ប្រចាំឆ្នាំ មិនមានការផ្លាស់ប្តូរទាក់ទងនឹងវិធាន រាយការណ៍ស្ម័គ្រចិត្តសម្រាប់ CalWORKs ទេ។ លោកអ្នកអាចរាយការណ៍ដោយស្ម័គ្រចិត្តអំពីព័ត៌មានទាំងឡាយ ( ដូចជា ប្រាក់ចំណូល ថយចុះ ឬអ្នកណាម្នាក់គ្មានប្រាក់ចំណូលពីចូលមកនៅផ្ទះលោកអ្នក ) ដែលអាចបង្កើនដល់បរិមាណជំនួយរបស់លោកអ្នក។ ប្រសិនបើលោកអ្នករាយការណ៍អំពីអ្វីមួយដោយស្ម័គ្រចិត្ត ដែលនាំដល់ការបន្ថយបរិមាណជំនួយរបស់លោកអ្នកនោះ ខោនធីនឹងមិនបន្ថយជំនួយលោកអ្នករហូតដល់លោកអ្នករាយការណ៍ព័ត៌មាននោះនៅលើរបាយការណ៍ដែលត្រូវធ្វើលើកក្រោយរបស់លោកអ្នក។

## វិធានរាយការណ៍អំពី Welfare-to-Work

ប្រសិនបើលោកអ្នកទទួលសេវា កម្មវិធីអន្តរកាលពីជំនួយសធារណៈទៅមុនការងារធ្វើ ( Welfare-to-Work ) លោកអ្នកត្រូវតែបន្តផ្តល់របាយការណ៍ និងសេចក្តីបញ្ជាក់ផ្សេងទៀតទាំងឡាយ ដែលខោនធីបានតម្រូវ។ លោកអ្នកចាំបាច់ត្រូវប្រគល់ភស្តុតាងបញ្ជាក់ពីបញ្ហានេះ ដើម្បីនៅបន្តទទួលសេវានេះ ដូចជា ការថែទាំក្មេង ការដឹកជញ្ជូន និងលុយសម្រាប់ទិញសៀវភៅ។